ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

## ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី អន្តរាគមជួយពលការិនីខ្មែរ៤នាក់

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរចំនួន**៤នាក់** ដូចខាងក្រោម៖

(១) ពលការិនី **ធ.ស** អាយុ២០ឆ្នាំ មកពីខេត្តកំពង់ស្ពឺ បានទៅម៉ាឡេស៊ី ធ្វើការជាអ្នកបោសសំអាត កាលពីខែសីហា ឆ្នាំ២០១៥។ ដោយការងារលំបាកពេក នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ នាងបានស្នើសុំស្ថានទូតជួយអន្តរាគមន៍។

(២) ពលការិនី **យ.សរ** អាយុ២៨ឆ្នាំ មកពីស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បានទៅម៉ាឡេស៊ីធ្វើការជាអ្នកបោសសំអាត ក្នុងខែធ្នូ ឆ្នាំ២០១៥។ ដោយធ្វើការលំបាកពេក នាងបានមកស្ថានទូត នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្នើសុំជួយជួយអន្តរាគមន៍។

(៣) ពលការិនី **សរ.យ** អាយុ៣៧ឆ្នាំ មកពីស្រុកគូលេន ខេត្តព្រះវិហារ បានទៅម៉ាឡេស៊ីធ្វើការជាអ្នកបោសសំអាត កាលពីខែមីនា ឆ្នាំ២០១៦។ ដោយការងារលំបាកពេក នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ នាងបានមកស្នើសុំអន្តរាគមន៍ពីស្ថានទូត។

ពលការិនីទាំង០៣រូបខាងលើ ទៅម៉ាឡេស៊ីតាមរយៈក្រុមហ៊ុនមួយ នៅកម្ពុជា។ ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជករបស់ពលការិនីទាំង០៣រូបខាងលើ បានយល់ព្រមប្រគល់លិខិតឆ្លងដែន និងប្រាក់ខែដែលនៅសល់ជូនពលការិនី។

(៤) ពលការិនី **ច.គន** អាយុ២៤ឆ្នាំ មកពីក្រុងប៉ៃលិន បានធ្វើដំណើរតាមរថយន្តកាត់តាមព្រំដែនថៃចូលទៅម៉ាឡេស៊ី ធ្វើការតាមផ្ទះ ក្នុងខែសីហា ឆ្នាំ២០១៤ តាមរយៈក្រុមហ៊ុនមួយ (មិនចាំឈ្មោះ) នៅកម្ពុជា។ ដោយធ្វើការលំបាកពេក នាងបានទៅស្ថានទូត នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៧ ស្នើសុំជួយទាមទារប្រាក់ខែពីនិយោជក និងជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជកបានយល់ព្រមប្រគល់ប្រាក់ខែដែលនៅសល់ជូននាង។ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគជូនពលការិនីទាំង **០៤រូប**ខាងលើ ហើយពួកគាត់បានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧** វេលាម៉ោង **០៧:៥០នាទីព្រឹក** តាមជើងយន្តហោះ AK 536 ។

ភ្នំពេញ, ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ